# លទ្ធផលសង្ខេបនៃការស្រាវជ្រាវ : ការអង្កេតតាមដានកម្មករនិយោជិតកាត់ដេរ

*ខែ មីនា ឆ្នាំ ២០១០*

## សារតា

អង្គការពលកម្មអន្តរជាតិ (ILO) បានធ្វើការអង្កេតតាមដានលើកម្មករនិយោជិតកាត់ដេរចំនួន ២០០០ នាក់ (១២០០នាក់មានការងារធ្វើ និង ៨០០ នាក់ពុំមានការងារធ្វើ) រយៈពេល ៦ ខែ ដើម្បីសិក្សាពីការលំបាកដែលពួកគេជួបប្រទះ ដោយសារតែការធ្លាក់ចុះសេដ្ឋកិច្ចជាសកល និងអំពីយុទ្ធសាស្ត្រដោះស្រាយ ការ លំបាក និង ស្វែង រក ការងារ ធ្វើ របស់ ពួក គេ។ ដោយទទួលបានការឧបត្ថម្ភពីកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ UNDP ហើយនឹងត្រូវបានអនុវត្តដោយវិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍន៍ (CIDS) ការសិក្សានេះនឹងបញ្ចប់នៅក្នុងឆ្នាំ ២០១០ (ត្រីមាសទី ៣)។ ការអង្កេតដាច់ដោយឡែកមួយទៀតក៏ត្រូវបានធ្វើឡើងផងដែរ ដើម្បីស្វែងយល់អំពីបញ្ហាប្រឈម ដែលក្រុមហ៊ុននានាបានជួបប្រទះកន្លងមក និងកំពុងបន្តជួបប្រទះនាពេលបច្ចុប្បន្ននេះ សម្រាប់ក្រុមហ៊ុនជាច្រើន និងអំពីយុទ្ធសាស្ត្រ ដែលក្រុមហ៊ុនទាំងនោះកំពុងប្រើប្រាស់ ដើម្បីទប់ទល់នឹងវិបត្តិនេះ។

ការសិក្សាកំណត់ចំណុចដៅដំបូងត្រូវបានធ្វើឡើងជាមួយកម្មករនិយោជិតមកពីរោងចក្រកាត់ដេរចំនួន ១៩៩ ដែលមានទីតាំងក្នុង និងជុំវិញទីក្រុងភ្នំពេញ ចាប់ពីខែ កញ្ញា ដល់ខែ ធ្នូ ឆ្នាំ ២០០៩។ ការសម្ភាសន៍តាមដានបន្តជាមួយកម្មករនិយោជិតដដែលនេះនឹងធ្វើឡើង ៣ និង ៦ ខែក្រោយពីបញ្ចប់ចំណុចដៅនេះរួច។

ការអង្កេតនេះមានការចូលរួមពីរោងចក្រផលិតសម្រាប់ការនាំចេញផង និងរោងចក្រដែលមិននាំចេញផង។[១] លទ្ធផលសង្ខេបនៃការស្រាវជ្រាវនេះបង្ហាញពីលទ្ធផលរកឃើញមួយចំនួន ដែលទទួលបានតាមរយៈការសម្ភាសន៍ជាមួយកម្មករនិយោជិត ធ្វើឡើងសម្រាប់ការអង្កេតកំណត់ចំណុចដៅ។

## លទ្ធផលរកឃើញសំខាន់ៗ

[១] ដើម្បីនាំចេញបាន រោងចក្រត្រូវចុះបញ្ជិកាជាមួយក្រសួងពាណិជ្ជកម្ម (MOC)។ ការសិក្សានេះកំណត់រោងចក្រនាំចេញថាជារោងចក្រដែលមានឈ្មោះនៅក្នុងបញ្ជិការបស់ក្រសួងពាណិជ្ជកម្ម ហើយរោងចក្រមិននាំចេញគឺជារោងចក្រ ដែលមិនមានឈ្មោះនៅក្នុងបញ្ជិកានេះ។ ជារឿយៗ រោងចក្រមិននាំចេញត្រូវបានរោងចក្រនាំចេញម៉ៅការបន្ត។

## លក្ខណៈទូទៅរបស់កម្មករនិយោជិត

កម្មករ និយោជិត ដែល មាន ការងារ ធ្វើ និង ដែល គ្មាន ការងារ ធ្វើ មាន លក្ខណៈ ស្រដៀង គ្នាៈ ៩០% ជាស្ត្រី ប្រហែលជា ៦៥% នៅលីវ ហើយភាគច្រើនមានអាយុចាប់ពីជាងម្ភៃឆ្នាំតិចតួចដល់ពាក់កណ្តាលម្ភៃ។ កម្មករនិយោជិតស្ទើរតែទាំងអស់ (៩៤%) មិនមានកម្រិតអប់រំលើសពីថ្នាក់ទី ៩ ឡើយ ហើយកម្មករនិយោជិត ៩៥% មកពីខេត្តជិតៗមកធ្វើការងារនៅក្នុងទីក្រុងភ្នំពេញ។ ជាមធ្យម កម្មករនិយោជិតជួយឧបត្ថម្ភសមាជិកគ្រួសារចំនួន ៣ នាក់ បន្ថែមពីលើពួកគេខ្លួនឯង។

## កម្មករនិយោជិតដែលមានការងារធ្វើ

ក្នុងចំណោមកម្មករនិយោជិតមានការងារធ្វើចំនួន ១២០០ នាក់ ដែលចូលរួមនៅក្នុងការអង្កេតនេះ **កម្មករនិយោជិតចំនួន ៦៧% កំពុងធ្វើការងារនៅក្នុងរោងចក្រនាំចេញ។ កម្មករនិយោជិតចំនួន ៣១% ចាប់ផ្តើមធ្វើការងារនៅក្នុងរោងចក្របច្ចុប្បន្នរបស់ពួកគេ នៅក្នុងឆ្នាំ ២០០៩។ កម្មករនិយោជិតជិតពាក់កណ្តាល (៤៩%) ធ្លាប់ធ្វើការងារក្នុងរោងចក្រកាត់ដេរផ្សេង ហើយជាងមួយភាគបី (២៧%) នៃកម្មករទាំងនេះត្រូវបានគេបញ្ឈប់ពីការងារ នៅក្នុងឆ្នាំ ២០០៩។** នេះបង្ហាញពីអត្រាចេញចូលក្នុងកម្រិតខ្ពស់របស់កម្មករនិយោជិត នៅក្នុងឧស្សាហកម្មកាត់ដេរ។

### <u>បញ្ហាលំបាកថ្មីៗ</u>

- កម្មករនិយោជិតដែលមានការងារធ្វើ **ថយចុះចំណូលរបស់ខ្លួនជាមធ្យមចំនួន ១៧ ដុល្លាក្នុងមួយខែ** ក្នុងឆ្នាំ ២០០៩ បើប្រៀបជាមួយឆ្នាំ ២០០៨។
- មូលហេតុសំខាន់នៃការថយចុះចំណូលគឺដោយសារ**ការកាត់បន្ថយការធ្វើការបន្ថែមម៉ោង** (កម្មករនិយោជិត ៥៣%) និង**ការកាត់ចំនួនម៉ោងធ្វើការធម្មតា** តាមរយៈការព្យួរការងារ និងការតម្រូវឱ្យឈប់សម្រាកពីការងារ។
- កម្មករនិយោជិតជាច្រើននាក់ (៣៩%) គិតថា**សេវាសុខភាព និងសុវត្ថិភាព នៅក្នុងរោងចក្ររបស់ពួកគេបានធ្លាក់ចុះ** ចាប់តាំងពីខែ មករា ឆ្នាំ ២០០៩ មក (ដែលមានដូចជា បន្ទប់ទឹកដែលអាចប្រើបានមានតិចជាងមុន ខ្យល់ចេញចូលមិនល្អដូចមុន និងមានថ្នាំពេទ្យតិចជាងមុននៅក្នុងគ្លីនិករបស់រោងចក្រ)។
- បើប្រៀបធៀបនឹងកាលពីឆ្នាំមុន ឥឡូវនេះមានកម្មករនិយោជិតច្រើនជាងមុនដែលមានអារម្មណ៍ថា **ពួកគេមិនមានលុយគ្រប់គ្រាន់សម្រាប់ផ្ញើរទៅផ្ទះ និងចំណាយលើតម្រូវការជាមូលដ្ឋាន** ដូចជាលើម្ហូបអាហារ ការថែទាំសុខភាព និងការធ្វើដំណើរ។

- **កម្មករនិយោជិតមានការងារធ្វើមួយចំនួន ដែលត្រូវបានគេបញ្ឈប់ពីការងារកាលពីពេលថ្មីៗនេះ និងរកការងារថ្មីបានធ្វើ កំពុងធ្វើការក្នុងលក្ខខណ្ឌការងារដែលមិនមានភាពប្រសើរដូចមុនៈ ១១% ធ្លាប់ជាកម្មករនិយោជិតពេញសិទ្ធិ ប៉ុន្តែឥឡូវនេះធ្វើជាកម្មករនិយោជិតម្តងម្កាល។**

<u>**យុទ្ធសាស្ត្រដោះស្រាយ**</u>

- **កម្មករនិយោជិតមានការងារធ្វើជិតពាក់កណ្តាល (៤៨,៥%) បានស្វែងរកជំនួយពីសហជីពដើម្បីដោះស្រាយបញ្ហាលំបាកថ្មីៗ** ដូចជាការថយចុះនូវលក្ខខណ្ឌសុវត្ថិភាព និងសុខភាព ការបើកប្រាក់ឈ្នួលយឺតយ៉ាវ និងការលំបាកក្នុងការសុំច្បាប់ឈប់ប្រចាំឆ្នាំ។ ក្នុងចំណោមកម្មករនិយោជិតដែលជាសមាជិករបស់សហជីព (៥៩% នៃកម្មករនិយោជិតមានការងារធ្វើ) ៨៦% បានទទួលដំបូន្មាន និងការប្រឹក្សាពីសហជីពរបស់ពួកគេ ហើយ ២% បានទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុ។
- **កម្មករនិយោជិតមួយចំនួន (២៣%) បានស្វែងរកជំនួយពីអ្នកពិនិត្យតាមក្រុមរបស់ពួកគេ** ពាក់ព័ន្ធជាមួយនឹងបញ្ហានៅក្នុងរោងចក្ររបស់ពួកគេ។
- ជាទូទៅ កម្មករនិយោជិតចូលធ្វើការងារនៅក្នុងវិស័យកាត់ដេរ ដើម្បីរកលុយឧបត្ថម្ភគ្រួសាររបស់ពួកគេ។ **ដូច្នេះ កម្មករនិយោជិតជាច្រើននាក់បានកាត់បន្ថយការចំណាយលើតម្រូវការជាមូលដ្ឋានរបស់ពួកគេដើម្បីអាចបន្តផ្ញើរលុយទៅផ្ទះបានទៀត។**
- **គ្រួសាររបស់កម្មករនិយោជិតចំនួន ១៤% បានបញ្ជូនសាច់ញាតិម្នាក់ទៀត - ជាធម្មតា គឺស្ត្រីដែលមានអាយុ ១៦-២៨ ឆ្នាំ - ដើម្បីស្វែងរកចំណូលបន្ថែម** នៅក្នុងទីក្រុង (ដែលគេអាចហៅបានថាជា«ផលប៉ះពាល់បន្ថែមលើកម្មករនិយោជិត»)។ កម្មករនិយោជិតបន្ថែមចំនួន៨នាក់ក្នុងចំណោម១០នាក់ មានបំណងរកការងារធ្វើនៅក្នុងវិស័យកាត់ដេរ។

## កម្មករនិយោជិតដែលគ្មានការងារធ្វើ [២]

កម្មករនិយោជិតដែលគ្មានការងារធ្វើភាគច្រើនបាត់បង់ការងារ ដោយសាររោងចក្របិទទ្វារ (៤៧%) ឬដោយសារតែការថយចុះនូវការបញ្ជាទិញដែលរោងចក្រទទួលបាន (៤២%)។ កម្មករនិយោជិតចំនួន ៩% បានលាឈប់ពីការងារដោយស្ម័គ្រចិត្ត ដោយសារចំណូលរបស់ពួកគេមានការថយចុះ។ កម្មករនិយោជិតគ្មានការងារធ្វើប្រហែលជា ១០% ត្រូវបានគេបញ្ឈប់ពីការងារយ៉ាងហោច

[២] កម្មករនិយោជិតដែលគ្មានការងារធ្វើ រួមមាន អ្នកដែលត្រូវបានគេបញ្ឈប់ការងារពីឧស្សាហកម្មកាត់ដេរចាប់តាំងពីថ្ងៃទី ១ ខែមករា ឆ្នាំ ២០០៩ មក។ បន្ថែមពីលើកម្មករនិយោជិត ដែលត្រូវបានគេបញ្ឈប់ពីការងារដោយសារតែរោងចក្របិទទ្វារ ឬកាត់បន្ថយផលិតកម្ម មានកម្មករនិយោជិតខ្លះលាឈប់ពីការងារដោយស្ម័គ្រចិត្ត ដោយសារតែការធ្វើការបន្ថែមម៉ោងមានតិចជាងមុន សប្តាហ៍ធ្វើការងារខ្លីជាងមុន ឬដោយសារកត្តាដទៃទៀត ដែលធ្វើឱ្យចំណូលរបស់ពួកគេមានការថយចុះ។

ណាស់ ២ ដងនៅក្នុងឆ្នាំ ២០០៩ – ដែលនេះជាសញ្ញាមួយទៀតបង្ហាញពីអត្រាចេញចូលកម្រិតខ្ពស់របស់កម្មករនិយោជិត នៅក្នុងឧស្សាហកម្មនេះ។ ជារួម ហាក់បីដូចជាពុំមានការខុសប្លែកគ្នាខ្លាំងរវាងលក្ខណៈ និងកម្រិតជំនាញរបស់កម្មករនិយោជិតគ្មានការងារ ដែលឥឡូវនេះ ពួកគេរកការងារថ្មីបានធ្វើ និងអ្នកដែលកំពុងបន្តរកការងារធ្វើ។[៣]

## ការបញ្ឈប់ពីការងារ

- មានតែ **កម្មករនិយោជិតគ្មានការងារធ្វើ មួយភាគបីប៉ុណ្ណោះ បានទទួលប្រាក់សំណងទូទាត់សម្រាប់ការបញ្ឈប់ការងារ** ពីនិយោជករបស់ពួកគេ។
- **ការផ្តល់ប្រាក់សំណងទូទាត់សម្រាប់ការបញ្ឈប់ពីការងារហាក់ដូចជាមានតាមរោងចក្រនាំចេញច្រើនជាងរោងចក្រមិននាំចេញ។** មានកម្មករនិយោជិត ១០% បន្ថែមទៀតក្នុងរោងចក្រនាំចេញដែលបានទទួលការទូទាត់សម្រាប់ការបញ្ឈប់ពីការងារ។
- **សមាជិកសហជីព (៣៩%) ទំនងជាទទួលបានប្រាក់សំណងសម្រាប់ការបញ្ឈប់ពីការងារ ជាងកម្មករនិយោជិតដែលមិនមែនជាសមាជិកសហជីព (២៨%)។**
- កម្មករនិយោជិតគ្មានការងារធ្វើចំនួនជាងបីភាគបួនមិនបានទទួលការជូនដំណឹងជាមុន មុនពេលត្រូវបានគេបញ្ឈប់ពីការងារ។
- ជាងពាក់កណ្តាលនៃកម្មករនិយោជិតគ្មានការងារធ្វើចំនួន ៨០០ នាក់ (៥៧%) គឺជាសមាជិករបស់សហជីពក្នុងរោងចក្រ។ សហជីពទាំងនេះផ្តល់ដំបូន្មានផ្នែកច្បាប់ (ដល់កម្មករនិយោជិតចំនួន ៣%) និងចូលរួមធ្វើសកម្មភាពក្នុងរោងចក្រក្នុងនាមតំណាងឱ្យសមាជិកចំនួន ៦០% ក្នុងកិច្ចខំប្រឹងប្រែងដើម្បី ដោះស្រាយ បញ្ហាដែល ពួកគេ ប្រឈម នៅក្នុងពេល ដែល ត្រូវបានគេបញ្ឈប់ពីការងារ។
- ជាធម្មតា កម្មករនិយោជិត (ទាំងមានការងារ និងគ្មានការងារ) **មានប្រាក់សន្សំតិចតួចប៉ុណ្ណោះ** ដើម្បីជួយពួកគេឱ្យរួចផុតពីការលំបាក។ កម្មករនិយោជិតដែលគ្មានការងារធ្វើជាច្រើននាក់កំពុងខ្ចីលុយពីគ្រួសារ និងមិត្តភ័ក្ត្រ ដើម្បីដោះទ័ល។

## តើកម្មករនិយោជិតដែលត្រូវបានគេបញ្ឈប់ពីការងារកំពុងធ្វើអ្វីខ្លះនាពេលបច្ចុប្បន្ននេះ

[៣] កម្មករនិយោជិតគ្មានការងារធ្វើ ត្រូវបានជ្រើសរើសពីខណ្ឌ ដែលពួកគេកំពុងរស់នៅ និងធ្វើការងារ ដោយប្រើវិធីសាស្ត្រកំណត់ប៉ាន់គំរូបែបចង្កោម ដែលដាក់ទម្ងន់ដោយភាគរយរបស់រោងចក្រដែលបានបិទទ្វារ នៅក្នុងខណ្ឌនោះ។ កម្មករនិយោជិតគ្មានការងារធ្វើដែលចូលរួមក្នុងការអង្កេតនេះប្រមាណបីភាគបួន មកពីខណ្ឌដង្កោ មានជ័យ និងឫស្សីកែវ។

- **កម្មករនិយោជិតចំនួន ១៦,៥% រកបានការងារធ្វើក្នុងរោងចក្រកាត់ដេរមួយទៀត** ហើយ ៦% រកបានការងារធ្វើ នៅក្នុងវិស័យដទៃទៀត (ដូចជា ផ្នែកសេវាកម្ម កសិកម្ម និងសេវាកម្សាន្តសប្បាយជាដើម)។[៤] **ប៉ុន្តែ ពួកគេភាគច្រើននៅកំពុងបន្តរកការងារថ្មីធ្វើ** (៦៣%)។
- មានកម្មករនិយោជិតមួយចំនួនតូចប៉ុណ្ណោះ (១២,៥%) ដែលបានវិលត្រឡប់ទៅផ្ទះវិញ ដើម្បីជួយការងារស្រែចម្ការរបស់គ្រួសារ ឬជួយការងារផ្ទះ។
- **កម្មករនិយោជិតដែលត្រូវបានគេបញ្ឈប់ពីការងារ ចង់រកការងារធ្វើនៅក្នុងវិស័យកាត់ដេរជាមុនសិន** (ជាជាងក្នុងវិស័យដទៃទៀត)។ អត្រាជោគជ័យនៃការរកការងារបានធ្វើនៅទីនេះគឺប្រហែលជា៣០%។
- ជាធម្មតា **អ្នកដែលរកការងារធ្វើនៅក្រៅវិស័យកាត់ដេរ ស្វែងរកការងារក្នុងវិស័យសេវាកម្ម** (ឧទាហរណ៍ អ្នកលក់រាយសម្លៀកបំពាក់ ហាងកាត់ដេរ ធ្វើជាអ្នកលក់ម្ហូប ឬជាអ្នករត់តុកតុក)។
- **កម្មករនិយោជិតដែលស្វែងរកជំនួយក្នុងការរកការងារធ្វើ ជាធម្មតា សុំជំនួយពីគ្រួសារ និងមិត្តភ័ក្រ្តជាមុនសិន។** បញ្ហាប្រឈមធំជាងគេ ដែលពួកគេជួបប្រទះក្នុងពេលស្វែងរកការងារធ្វើ គឺកង្វះខាតប្រាក់កាស ដើម្បីរ៉ាប់រងចំណាយសម្រាប់ការរស់នៅ។
- **កម្មករនិយោជិតដែលរកការងារធ្វើបានក្រៅវិស័យកាត់ដេរមានតែ ៨% ប៉ុណ្ណោះដែលបានទទួលការបណ្តុះបណ្តាល** ដើម្បីធានាភាពជាប់លាប់នៃការងារថ្មីរបស់ពួកគេ (ផ្នែកកាត់ដេរសម្លៀកបំពាក់ ម៉ាស្សា គ្រូបង្រៀន និងធ្វើជាសន្តិសុខ)។
- **កម្មករនិយោជិតភាគច្រើន ដែលរកការងារបានធ្វើក្រៅវិស័យកាត់ដេរទទួលបានចំណូលជាមធ្យម ២៤ ដុល្លាក្នុងមួយខែចំពោះការងារថ្មីរបស់ពួកគេ។** ជាធម្មតា ការងារថ្មីៗទាំងនេះត្រូវបានគេចាត់ទុកថាជាការងារបណ្តោះអាសន្ន ឬការងារអន្តរកាល។
- មាន**ការចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលតិចតួចបំផុត** (តិចជាង ២%) ដោយភាគច្រើនមានការចុះឈ្មោះចូលរួមក្នុងការបណ្តុះបណ្តាលអំពីការរចនាម៉ូដសម្លៀកបំពាក់ ឬព្យាបាលកែសម្ផស្ស។
- កម្មករនិយោជិតភាគច្រើនចង់ចូលរួមក្នុងការបណ្តុះបណ្តាល ប៉ុន្តែពួកគេ**ត្រូវការប្រាក់ឧបត្ថម្ភ និងប្រាក់សម្រាប់កន្លែងស្នាក់នៅ ដើម្បីអាចចូលរួមបាន។** កម្មករនិយោជិតជាច្រើននាក់ចង់ចូលរួមក្នុងវគ្គបណ្តុះបណ្តាលខ្លីៗ ដែលពេលរៀនមានការបត់បែន ដើម្បីឱ្យពួកគេអាចធ្វើការផងរៀនផង។

---

[៤] ដោយសារការពាក់ព័ន្ធ និងការជាប់ទាក់ទងជាមួយអាជីវកម្មផ្លូវភេទ ចលនារបស់កម្មករនិយោជិតកាត់ដេរចូលទៅក្នុងវិស័យកម្សាន្តសប្បាយទំនងមិនត្រូវបានគេរាយការណ៍អស់ឡើយ។ សម្រាប់ព័ត៌មានបន្ថែម សូមមើល *ប្រទេសកម្ពុជាៈ ការចូលទាំងក្រុមទៅក្នុងអាជីវកម្មផ្លូវភេទ? ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុជាសកល មកលើលក្ខខណ្ឌការងារ និងឱកាសរបស់ស្ត្រី* (មិថុនា ២០០៩) www.no-trafficking.org។

- **កម្មករនិយោជិតចំនួនបីភាគបួននិយាយថាពួកគេនឹងត្រឡប់ទៅផ្ទះ ដើម្បីធ្វើស្រែចម្ការឱ្យគ្រួសារវិញ** ប្រសិនបើមួយខែក្រោយមក ពួកគេនៅតែមិនអាចរកការងារបានធ្វើ។

***<u>កម្មករនិយោជិតគ្មានការងារធ្វើកំពុងដោះស្រាយបញ្ហាលំបាក ដោយៈ</u>***

- ***ខ្ចីលុយគេៈ*** កម្មករនិយោជិតជាច្រើននាក់ (៤២%) ខ្ចីលុយភាគច្រើនពីគ្រួសារ ឬមិត្តភ័ក្ត្រ (រួមគ្នា ៧៨%)។ កម្មករនិយោជិតផ្សេងទៀតខ្ចីលុយពីអ្នកចងការប្រាក់ (១២%) ម្ចាស់ផ្ទះជួល (៤%) និងធនាគារ (២%)។
- ***ប្រើប្រាស់ប្រាក់សំណងបញ្ឈប់ការងារ ដែលទទួលបានពីរោងចក្រៈ*** កម្មកនិយោជិតជាច្រើននាក់ដែលបានទទួលប្រាក់សំណងសម្រាប់ការបញ្ឈប់ការងារប្រើប្រាស់លុយនេះ ដើម្បីជួយរ៉ាប់រងការចំណាយសម្រាប់ការរស់នៅរបស់ពួកគេ។
- ***សុំជំនួយពីគ្រួសារ ឬប្រពន្ធប្តីៈ*** កម្មករនិយោជិតគ្មានការងារធ្វើចំនួនមួយភាគបីទទួលបានការឧបត្ថម្ភពីគ្រួសារ និងសាច់ញាតិរបស់ពួកគេជាម្ហូបអាហារ និងកន្លែងស្នាក់នៅ។ មានកម្មករនិយោជិតគ្មានការងារធ្វើជិតមួយភាគប្រាំទទួលបានការឧបត្ថម្ភពីចំណូលរបស់ប្តី ឬប្រពន្ធរបស់ពួកគេ (១៩%)។
- ***ប្រើប្រាស់ប្រាក់សន្សំផ្ទាល់ខ្លួនៈ*** កម្មករនិយោជិតគ្មានការងារធ្វើចំនួន ៣០% អាចសន្សំលុយបានខ្លះ ពេល កំពុង មាន ការងារ ធ្វើ ពី មុន មក ប៉ុន្តែ ពួកគេ ស្ទើរ តែ ទាំង អស់ បាន ប្រើ លុយ នេះ មួយចំនួន ឬទាំងអស់អស់ហើយ។
- ***ទទួលយកការងារធ្វើជាបណ្តោះអាសន្នៈ*** កម្មករនិយោជិតមួយចំនួន (៦%) ធ្វើការងារបណ្តោះអាសន្ន ដូចជា ធ្វើជាកម្មករនិយោជិតម្តងម្កាលតាមរោងចក្រ លក់ទឹកអប់ វត់តុកតុក កាត់ដេរ និងធ្វើក្រចក។
- ***គ្រួសារបញ្ជូនសមាជិកបន្ថែមទៀតឱ្យមករកការងារធ្វើៈ*** គ្រួសារកម្មករនិយោជិតចំនួន ១១% បានបញ្ជូនសមាជិកគ្រួសារម្នាក់បន្ថែមទៀតឱ្យមករកការងារធ្វើក្នុងទីក្រុង។ ក្នុងករណីជិត ៩០% កម្មករនិយោជិតទាំងនេះស្វែងរកការងារធ្វើនៅក្នុងវិស័យកាត់ដេរ។

## អនុសាសន៍ជាជំហានដំបូង

ផ្អែកតាមលទ្ធផលនៃការអង្កេតនេះ និងទៅតាមការងារពាក់ព័ន្ធនឹងវិបត្តិដទៃទៀត អនុសាសន៍ខាងក្រោមនេះត្រូវបានលើកឡើងៈ

***<u>សកម្មភាពរបស់រដ្ឋាភិបាល</u>***

១. **បង្កើតគោលនយោបាយមុខរបរ** ដើម្បីលើកកម្ពស់មុខរបរ/ការងារប្រកបដោយផលិតភាពតាមរយៈ

- គោលនយោបាយ ម៉ាក្រូ សេដ្ឋកិច្ច និង គោល នយោបាយ តាមវិស័យ ដែល មាន លក្ខណៈ ជាយុទ្ធសាស្ត្រ។ នេះរួមមានគោលនយោបាយពង្រីកប្រភពសេដ្ឋកិច្ច ទៅក្នុងវិស័យដទៃទៀត ដែល

កំពុងមានការរីកចម្រើន និងកំពុងស្រូបយកកម្លាំងពលកម្ម ដូចជាការអភិវឌ្ឍន៍វិស័យទេសចរណ៍ និងការធ្វើទំនើបកម្មកសិកម្មជាដើម។

- គោលនយោបាយអភិវឌ្ឍន៍ជំនាញសមស្រប - ពិនិត្យឡើងវិញ និងកែលំអគោលនយោបាយ និង ប្រព័ន្ធអប់រំ អភិវឌ្ឍន៍ ជំនាញ និង បណ្តុះ បណ្តាល ដើម្បី ឱ្យ យុវជន អាច បំពេញបានទៅតាម តម្រូវការជំនាញនាពេលអនាគត។
- គាំទ្រដល់កម្មវិធីបណ្តុះបណ្តាលឡើងវិញ ដោយសហការជាមួយនិយោជក ដើម្បីធានាយ៉ាងណា ឱ្យកម្មករនិយោជិតមានជំនាញអាចធ្វើការងារនៅក្នុងវិស័យដទៃទៀតបាន។
- បង្កើត សេវាមុខរបរសាធារណៈ និង ប្រព័ន្ធព័ត៌មានទីផ្សារ ការងារ ដែល អាច បំពេញ មុខងារ យ៉ាង មានប្រសិទ្ធភាព។
- សម្របសម្រួលការស្វែងរកការងារធ្វើ ដោយ
  - រៀបចំពិពណ៌ការងារ
  - ផ្សព្វផ្សាយព័ត៌មានអំពីការជ្រើសរើសបុគ្គលិក (ក្នុងវិស័យកាត់ដេរ និងវិស័យផ្សេងទៀត)
  - បង្កើតទីតាំងច្រកចេញចូលតែមួយសម្រាប់សេវាការងារ និងផ្តល់ព័ត៌មានអំពីការបណ្តុះ បណ្តាល
  - សម្របសម្រួលការទទួលបានឥណទានសម្រាប់ឱ្យអ្នកគ្មានការងារធ្វើរ៉ាប់រងលើការចំណាយ ស្វែងរកការងារ ឬសម្រាប់ចាប់ផ្តើមអាជីវកម្មដោយខ្លួនឯង (ប្រកបមុខរបរដោយខ្លួនឯង)
- លើកកម្ពស់កម្មវិធីសាធារណការ ដើម្បីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដែលចាំបាច់។
- លើកកម្ពស់ ការងារ បៃតង ដែល ទទួល បាន ការ ឧបត្ថម្ភ ថវិកា ជាសាធារណៈ ដូចជា ផ្តល់ថវិកា សម្រាប់ការអភិរក្សតំបន់បេតិកភ័ណ្ឌជាតិជាដើម
- លើកកម្ពស់សហគ្រាសខ្នាតតូច និងមធ្យម តាមរយៈការផ្តល់កម្ចីសម្រាប់ចាប់ផ្តើមអាជីវកម្មខ្នាត តូច
- លើកកម្ពស់សមភាពយេនឌ័រ និងការងារសម្រាប់ស្ត្រី
- គាំទ្រដល់សហគ្រាស នៅក្នុងការកែសម្រួលរចនាសម្ព័ន្ធរបស់ពួកគេ សម្រាប់បង្កើនប្រសិទ្ធភាព នៅក្នុងវិស័យកាត់ដេរ តាមរយៈ
  - ការបង្កើតគោលនយោបាយ ដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងតាមរយៈការបង្កើន ជំនាញ (ដូចជា កម្មវិធីបណ្តុះបណ្តាលឡើងវិញ) និងធ្វើឱ្យមានទីផ្សារចម្រុះ
  - ការជួយរោងចក្រកាត់បន្ថយចំណាយក្នុងផលិតកម្មឱ្យនៅកម្រិតអប្បបរមា (ជាជាងកាត់ បន្ថយប្រាក់ឈ្នួល) តាមរយៈការផ្តល់ឧបត្ថម្ភធនផ្នែកអគ្គិសនី និងសេវាប្រើប្រាស់ ការ ដឹកជញ្ជូន ឬតាមរយៈការលើកលែងពន្ធ

## ២. **<u>បង្កើនកិច្ចការពារសង្គម</u>**

- ធានាថាយុទ្ធសាស្ត្រសំណាញ់សុវត្ថិភាពសង្គមថ្នាក់ជាតិនាពេលខាងមុខគឺបំពេញបាននូវតម្រូវការរបស់កម្មករនិយោជិតកាត់ដេរ និងគ្រួសាររបស់ពួកគេ ហើយនឹងបង្កើតឱ្យមានលក្ខណៈទូលំទូលាយច្រើននៃកំណែទម្រង់ និងការវិនិយោគទុនដើម្បីបង្កើតប្រព័ន្ធការពារសង្គម ដែលមានលក្ខណៈទូលំទូលាយ។
- គន្លឹះចំពោះការបង្កើនកិច្ចការពារសង្គមនឹងជាការអភិវឌ្ឍន៍នូវសមាសភាពសំខាន់ៗនៃកម្រិតសង្គមជាមូលដ្ឋាន ដែលរួមមាន
    - ការទទួលបាននូវផលប្រយោជន៍នៃការថែទាំសុខភាពជាមូលដ្ឋាន (ឧទាហរណ៍ តាមរយៈមូលនិធិធានារ៉ាប់រងសុខភាពសង្គម និងមូលនិធិសមភាពសុខភាព)
    - សន្តិសុខប្រាក់ចំណូលសម្រាប់កុមារ តាមរយៈផលប្រយោជន៍ដែលបានមកពីគ្រួសារ
    - ជំនួយផ្នែកសង្គមដែលដៅលើខ្លួនឯងសម្រាប់ជនក្រីក្រ និងអ្នកគ្មានការងារធ្វើ ដូចជាតាមរយៈគោលការណ៍កិច្ចអភិវឌ្ឍន៍ជំនាញ
    - ការផ្តល់ប្រាក់សោធននិវត្តន៍ជាសកល
    - ការបញ្ជូនប្រាក់តាមលក្ខខណ្ឌ - លក្ខខណ្ឌលើសុខភាព និងលទ្ធផលនៃការអប់រំដល់ស្ត្រី និងកុមារ។

## ៣. <u>បង្កើនការអនុលោមតាមច្បាប់</u>

ធានាថារោងចក្រអនុលោមទៅតាមច្បាប់ស្តីពីការងារ ជាពិសេសពាក់ព័ន្ធជាមួយការទូទាត់សំណងសម្រាប់ការបញ្ឈប់ពីការងារ និងការជូនដំណឹងជាមុន។

### ***សកម្មភាពធ្វើឡើងដោយនិយោជក***

- ប្រើប្រាស់ពេលវេលា ដែលផលិតកម្មមានការថយចុះ ដើម្បីបណ្តុះបណ្តាលកម្មករនិយោជិតឡើងវិញ និងបង្កើនជំនាញរបស់កម្មករនិយោជិត។
- ប្រឹក្សាជាមួយសហជីព មុនពេលបញ្ឈប់កម្មករនិយោជិតច្រើននាក់ ឬបិទទ្វាររោងចក្រ។
- អនុលោមទៅតាមច្បាប់ពាក់ព័ន្ធនឹងការជូនដំណឹងជាមុនអំពីការបញ្ឈប់ការងារ និងការទូទាត់សំណងសម្រាប់ការបញ្ឈប់ការងារ។

### ***សកម្មភាពរបស់សហជីព***

- ស្វែងរកឱកាសសន្ទនាប្រកបដោយលក្ខណៈស្ថាបនាជាមួយអ្នកគ្រប់គ្រងរបស់រោងចក្រ។
- ជូនដំណឹងដល់កម្មករនិយោជិតអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគេ ពាក់ព័ន្ធនឹងការជូនដំណឹងជាមុន និងប្រាក់សំណងសម្រាប់ការបញ្ឈប់ពីការងារ។
- តាមដានការអនុលោមតាមច្បាប់ស្តីពីការងារ (ជាពិសេសពាក់ព័ន្ធនឹងការបញ្ឈប់កម្មករនិយោជិតពីការងារ) និងចូលរួមយ៉ាងសកម្មជាមួយនិយោជក ដើម្បីធានាយ៉ាងណាឱ្យកម្មករនិយោជិតដែលត្រូវបានគេបញ្ឈប់ពីការងារទទួលបានអ្វីដែលពួកគេត្រូវទទួលបាន។

- ជួយក្នុងការផ្តល់ព័ត៌មានអំពីការងារថ្មីៗដល់បុគ្គលិក ដែលត្រូវបានគេបញ្ឈប់ពីការងារ។

### *សកម្មភាពរបស់ដៃគូអភិវឌ្ឍន៍*

- ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដល់កម្មវិធីបណ្តុះបណ្តាលឡើងវិញ។
- គាំទ្រដល់កម្មវិធីសង្គម ដែលអាចជួយកាត់បន្ថយការចំណាយរបស់កម្មករនិយោជិតលើតម្រូវការជាមូលដ្ឋាន ដូចជាការថែទាំសុខភាព ជាដើម។
- ធ្វើការងារជាមួយសហជីព ដើម្បីបង្កើនសមត្ថភាពរបស់ពួកគេ ក្នុងការផ្តល់ជំនួយប្រកបដោយអត្ថន័យដល់កម្មករនិយោជិត។
- *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* គួរបន្តពិនិត្យតាមដានលក្ខខណ្ឌការងារនៅតាមរោងចក្រនានា និងពិនិត្យរកសញ្ញា ដែលបង្ហាញថារោងចក្រអាចបិទទ្វារ។